**អង្គការសមាគមធាងត្នោត**

**Sahmakum Teang Tnaut Organization** • a Cambodian Urban NGO

លេខៈ ១០១/២៥

# សេចក្តីជូនដំណឹង

## ស្តីពី ការអញ្ជើញចូលរួមដេញថ្លៃ
## លើការផ្គត់ផ្គង់កញ្ចប់សេវាកម្មអាហារ និងទីកន្លែងសម្រាប់វគ្គបណ្តុះបណ្តាល
## សិក្ខាសាលា ការប្រជុំ និងកម្មវិធីផ្សេងៗ នៅរាជធានីភ្នំពេញ

អង្គការសមាគមធាងត្នោត (ស.ធ.ត.) គឺជាអង្គការឯករាជ្យ មិនស្វែងរកប្រាក់ចំណេញ បានបង្កើតឡើងតាំងពីឆ្នាំ២០០៥ និងបានចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦។

អង្គការសមាគមធាងត្នោត សូមអញ្ជើញសណ្ឋាគារ ភោជនីយដ្ឋាន និងក្រុមហ៊ុននានាដែលមានទទួលផ្គត់ផ្គង់សេវាកម្មដូចបានបញ្ជាក់ខាងលើ ដើម្បីចូលរួមដេញថ្លៃលើការផ្គត់ផ្គង់សេវាកម្មរៀបចំអាហារ និងទីកន្លែងសម្រាប់វគ្គបណ្តុះបណ្តាល សិក្ខាសាលា ការប្រជុំ និងកម្មវិធីផ្សេងៗ សម្រាប់ឆ្នាំ២០២៦។ ដើម្បីចូលរួមដេញថ្លៃ និងចំពោះព័ត៌មានពាក់ព័ន្ធនឹងការដាក់ដេញថ្លៃ សូមទាញយកទម្រង់សម្រង់តម្លៃ និងបំពេញលក្ខខណ្ឌតម្រូវនានាដើម្បីផ្តល់សម្រង់តម្លៃ ។

**<u>លក្ខខណ្ឌដែលក្រុមហ៊ុនត្រូវមាន៖</u>**

- លិខិតប្រកបអាជីវកម្ម ឬ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬ ប័ណ្ណប៉ាតង់ ដែលមានសុពលភាព
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ
- លិខិតបញ្ជាក់ទីតាំងក្រុមហ៊ុន និង អត្តសញ្ញាណប័ណ្ណម្ចាស់ក្រុមហ៊ុន
- ផ្តល់នូវលិខិតសម្រង់តម្លៃ លើកញ្ចប់សេវាកម្មដែលបានរៀបរាប់ខាងលើ

**<u>បែបបទនៃការដាក់ពាក្យ៖</u>**

ក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍ សូមផ្តល់នូវលិខិតសម្រង់តម្លៃ ដោយភ្ជាប់ជាមួយនឹងឯកសារច្បាប់នានាដែលបានតម្រូវក្នុងលក្ខខណ្ឌខាងលើ ដាក់ក្នុងស្រោមសំបុត្របិទជិត រួចផ្ញើមកកាន់អាសយដ្ឋានរបស់អង្គការសមាគមធាងត្នោត ផ្ទះលេខ២១ ផ្លូវ៤៧២ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**<u>កាលបរិច្ឆេទឈប់ទទួលពាក្យ៖</u>**

ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥ វេលាម៉ោង ០៥ រសៀល ។

ប្រធានផ្នែករដ្ឋបាល និងធនធានមនុស្ស

អង្គការសមាគមធាងត្នោត * Sahmakum Teang Tnaut Organization *

លោក សួស សុភាព

កាលបរិច្ឆេទ៖ ១៦ ធ្នូ ២០២៥

អាសយដ្ឋាន៖ ផ្ទះលេខ ២១ ផ្លូវលេខ ៤៧២ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរសព្ទលេខ (៨៥៥)២៣ ៤៣១ ៥៥៥
ប្រអប់សំបុត្រលេខ ១៧៤ ភ្នំពេញ កម្ពុជា។ អ៊ីមែល info@teangtnaut.org គេហទំព័រ: www.teangtnaut.org
Address: #21, St 472, Sangkat Toul Tompoung 1, Khan Chamkarmorn, Phnom Penh, Cambodia Tel: (855) 23 431 555
P.O. Box 174, Phnom Penh, Cambodia. E-mail. info@teangtnaut.org Web. www.teangtnaut.org